# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ធម៌ជាគ្រឿងចំរើនបួនយ៉ាង ។

www.hoksavann,com

ថ្ងៃទី២០ មករា ២០១១



ធម៌ជាគ្រឿងចំរើនបួនយ៉ាង បាលីថាវុឌ្ឍិធម៌ ប្រែជាសេចក្តីថា ធម៌ធ្វើឲ្យអ្នកប្រតិបត្តិតាម បានចំរើនសីលធម៌ផង ចំរើនសម្ភារៈផង ដូចសេចក្តីអធិប្បាយតទៅនេះ ៖

១- សប្បុរិសូបសំសេវៈ ប្រែថា ការចូលទៅជិតសេពគប់សប្បុរស ។ ពាក្យថា សប្បុរស បានដល់បុគ្គលដែលប្រព្រឹត្តល្អ ដោយកាយវាចាចិត្ត ឬជាអ្នកស្អប់អំពើបាបគ្រប់យ៉ាង ឬអាចហៅពាក្យជំនួសមួយទៀតថាបណ្ឌិត ។ សប្បុរសជាបុគ្គលដែលបានទូន្មានខ្លួនយ៉ាងល្អ តែងស្ថិតនៅក្នុងកុសលធម៌ជានិច្ច ធ្វើប្រយោជន៍ខ្លួន និង ប្រយោជន៍សង្គមឲ្យចំរើនលូតលាស់ ។ លក្ខណៈរបស់សប្បុរសតែងមានចិត្តជួយឈឺឆ្អាលនឹងសេចក្តី ទុក្ខរបស់អ្នកដទៃ ហើយចង់ឲ្យគេបានសុខ ។ ដូច្នេះអ្នកដែល បានចូលទៅជិតសេពគប់លោក រមែងបានទទួលនូវគំនិតដ៏ល្អៗ សំរាប់មាគ៌ាជីវិតឆ្ពោះទៅរកសេចក្តីសុខចំរើន ។ នៅក្នុងមង្គលសូត្រមានធម៌មួយកន្លែងពោលស្របគ្នាដែរថា កុំសេពគប់នឹងជនពាល ត្រូវសេពគប់នឹងបណ្ឌិត ឬសប្បុរស ទើបមានសេចក្តីសុខចំរើន ។ ព្រះសម្មាសម្ពុទ្ធជាសប្បុរសយ៉ាងខ្ពង់ខ្ពស់បំផុត ហើយអាណិតសព្វសត្វដែលមានទុក្ខយ៉ាងខ្ពស់បំផុត ព្រោះបន្ទាប់ពីត្រាស់ដឹង ព្រះអង្គបានសំដែងធម៌ទេសនាប្រោសសត្វអស់រយៈកាល៤៥ព្រះវស្សា ។ ជនណាបានទៅថ្វាយបង្គំ ហើយបានស្តាប់ធម៌ដែលព្រះអង្គសំដែង ហើយ យកមកប្រតិបត្តិតាម ជននោះនឹងរួចចាកទុក្ខ មានជាតិទុក្ខជាដើម ។

២- សុទ្ធម្មស្សវនៈ ប្រែថាស្តាប់ពាក្យប្រៀនប្រដៅរបស់លោកដោយគោរព ។ បានសេចក្តីថា បន្ទាប់ពីបានចូលទៅជិតសេពគប់នឹងសប្បុរសហើយ ត្រូវយកចិត្តទុកដាក់ស្តាប់ពាក្យរបស់ លោកដោយសេចក្តីគោរព ។ចំណេះដឹងគ្រប់យ៉ាងកើតឡើង ពីការសិក្សារៀនសូត្រនិងការស្តាប់នេះឯង ។ បើស្តាប់ហើយកន្លែ ងណាមិនយល់ត្រូវសាកសួរ ហើយត្រូវកត់ទុកក្រែងភ្លេចថ្ងៃក្រោយ ។ បើជួបលោកអ្នកចេះដឹងហើយ ពុំបានស្តាប់ពាក្យប្រៀ បប្រដៅរបស់លោកទេ ការជួបនោះពុំមានប្រយោជន៍ឡើយ ។ ក្នុងព្រះពុទ្ធសាសនា លោកអ្នកដែលបានសំរេចមគ្គផលនិព្វន តួយ៉ាងដូចជាព្រះអរហន្ត ដោយសារបានស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហើយយកមកប្រតិបត្តិតាម ។

៣- យោនិសោមនសិការៈ ប្រែថា ការធ្វើទុកក្នុងចិត្តដោយ ឧបាយកលនៃប្រាជ្ញា ។ សេចក្តីថា បើបានស្តាប់ពាក្យប្រៀនប្រដៅរបស់លោកអ្នកសប្បុរសហើយ ត្រូវយកមកគិតពិចារណា ឲ្យយល់សេចក្តីច្បាស់លាស់ ។ បើកន្លែងណាមិនយល់ច្បាស់ត្រូវសាកសួរបញ្ជាក់ ដើម្បីកុំឲ្យធ្វើទុកក្នុងចិត្តខុស ។ បើស្តាប់ហើយ ពុំបានពិចារណាឲ្យដក់ជាប់នៅក្នុងចិត្តទេ ការស្តាប់នោះពុំបានផលអ្វីឡើយ ព្រោះពុំបានចាំនៅក្នុងចិត្ត ។ បញ្ញាមួយផ្នែកនេះ គឺកើតពីការស្តាប់ តែដើម្បីឲ្យចងចាំច្បាស់លាស់ ត្រូវត្រិះរិះពិចារណាឲ្យស្ថិតជាប់ក្នុងចិត្ត ដែលហៅថា ចិន្តាមយបញ្ញា ។ ក្នុងន័យនេះ សូម្បីធម៌ដែលព្រះពុទ្ធសំដែង ក៏ព្រះអង្គតែងតែរំឭកថា ចូរអ្នករាល់គ្នាយកធម៌ដែលតថាគតសំដែងទៅពិចារណាទៀត មុននឹងជឿតថាគត ។ ត្រង់ពាក្យរំឭកនេះ ក្នុងព្រះបំណងឲ្យមនុស្សសត្វប្រើបញ្ញាពិចារណាឲ្យយល់ច្បាស់ខ្លួនឯង មិនត្រូវជឿអ្នកដទៃ ដោយពុំបានយល់ច្បាស់ខ្លួនឯងឡើយ ។

៤- ធម្មានុធម្មប្បដិបត្តិ ប្រែថា ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ សេចក្តីថា បើពិចារណាយល់សេចក្តីនូវធម៌នោះហើយ ត្រូវយកមកប្រតិបត្តិទៀត ទើបសំរេចប្រយោជន៍បាន ។ បើគ្រាន់ដឹងផ្លូវទៅកាន់សេចក្តីសុខ ប៉ុន្តែពុំបានដើរទៅទេ សេចក្តីសុខ ក៏ពុំអាចសំរេចបានឡើយ ។ យ៉ាងណាមិញ ពុទ្ធបរិស័ទចង់រួចចាកទុក្ខ សំរេចព្រះនិព្វន ត្រូវព្យាយាមស្តាប់ធម៌ទេសនាផ្លូវទៅនិព្វន ត្រង់មគ្គប្រកបដោយអង្គ៨ រួចប្រតិបត្តិតាម ។ ពាក្យថាប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ បានសេចក្តីថា ប្រតិបត្តិត្រឹមត្រូវតាមផ្លូវធម៌ មិនឲ្យឃ្លៀងឃ្លាតរហូតដល់ទីបំផុត ។ ធម៌ទាំង៤ប្រការនេះតែងមានទំនាក់ទំនងគ្នា បើពុំបានអនុវត្តផ្នែកណាមួយ ពុំអាចសំរេចប្រយោជន៍ឡើយ ។ ធម៌ទាំង៤ប្រការនេះ សំរាប់ប្រតិបត្តិទៅរកសេចក្តីសុខចំរើនផ្នែកកុសល ។ ប៉ុន្តែគេអាចយកទៅអនុវត្តឲ្យចំរើនលូតលាស់ខាងសម្ភារៈ សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ ។ ឧទាហរណ៍ ដើម្បីឲ្យចំរើនលូតលាស់ផ្នែកសង្គមកិច្ច ឲ្យប្រជាពលរដ្ឋរស់នៅមានជីវភាពខ្ពង់ខ្ពស់ គេធ្វើផែនការឲ្យប្រជាពលរដ្ឋ ជាពិសេសសិស្សនិងនិស្សិត ឲ្យសិក្សាចេះដឹងនូវបច្ចេកទេសគ្រប់យ៉ាង ពីសាស្ត្រាចារ្យជំនាញការគ្រប់ផ្នែក ហើយយកមកអនុវត្តតាម ។ ប៉ុន្តែគោលធម៌ទាំង៤ដូចបានពោលមកហើយ ចាត់ជាមូលដ្ឋានសំខាន់ ក្នុងការធ្វើឲ្យមានការចំរើនលូតលាស់ខាងសម្ភារៈចិញ្ចឹមជីវិត និងខាងសីលធម៌ ។៚

☆ ☆

☆